**ព្រះរាជាណាចក្រកម្ពុជា**

**KINGDOM OF CAMBODIA**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប**

**ASIA EURO UNIVERSITY**

លេខ:.....០០៥/១០.....ស.អ.អ

# សេចក្ដីសម្រេច
## ស្ដីពី
## គោលការណ៍បង់ថ្លៃសិក្សាថ្នាក់បណ្ឌិត

## សាកលវិទ្យាធិការ

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ ស្ដីពីការទទួលស្គាល់ការប្រែក្លាយពីវិទ្យាស្ថាន អាស៊ី អឺរ៉ុប ទៅជាសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

-បានឃើញប្រកាសលេខ ២០៨៥ អយក.ប្រក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតជាភាសាជាតិនៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប របស់ក្រសួងអប់រំ យុវជន និងកីឡា

-សេចក្ដីសម្រេចលេខ ០០៣/០៩ ស.អ.អ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ ស្ដីពីគោលការណ៍នៃការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

-យោងតាមសំណូមពរចាំបាច់នៃការបណ្ដុះបណ្ដាលក្រោយឧត្ដមសិក្សា

## សម្រេច

**ប្រការ១.-គោលដៅ**

សេចក្ដីសម្រេចនេះ មានគោលដៅកំណត់អំពី គោលការណ៍និងនីតិវិធីសម្រាប់ការបង់ថ្លៃសិក្សារបស់និស្សិតថ្នាក់បណ្ឌិតនិងបេក្ខជនបណ្ឌិត ក្នុងរយៈពេលដែលបានចុះឈ្មោះនិងទទួលយកសេវាបណ្ដុះបណ្ដាលនិងស្រាវជ្រាវថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ។

និស្សិតថ្នាក់បណ្ឌិត និងបេក្ខជនបណ្ឌិត តទៅត្រូវហៅថា និស្សិតបណ្ឌិត។

**ប្រការ២.-គោលបំណង**

សេចក្ដីសម្រេចនេះ មានគោលបំណងជួយសម្រួលដល់និស្សិតបណ្ឌិត ក្នុងការរៀបចំខ្លួនជាបណ្ដើរសម្រាប់ការចំណាយនានាក្នុងរយៈពេលនៃដំណើរការបណ្ដុះបណ្ដាលនិងស្រាវជ្រាវ រហូតបញ្ចប់ការសិក្សាដោយជោគជ័យ។

**ប្រការ៣.-រយៈពេលបណ្ដុះបណ្ដាលនិងស្រាវជ្រាវ(សិក្សា)**

និស្សិតបណ្ឌិត មានរយៈពេលសិក្សាអប្បរមាសរុបចំនួន ៣ឆ្នាំ និងអតិប្បរមាសរុបចំនួន ៦ឆ្នាំ ហើយដែលមានក្រេឌីតសរុបចំនួន ៦០ក្រេឌីត។

រយៈពេលសិក្សា ត្រូវកំណត់ដោយប្រតិទិនសិក្សាថ្នាក់បណ្ឌិតតាមជំនាន់និងវគ្គសិក្សានីមួយៗរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប។

**ប្រការ៤.-តម្លៃសិក្សាក្នុងរយៈពេលសិក្សាអប្បរមា**

និស្សិតដែលបានសម្រេចចិត្តចុះឈ្មោះចូលសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវបង់ថ្លៃសិក្សា សម្រាប់រយៈពេលសិក្សាអប្បរមា សរុបចំនួន ៣ឆ្នាំ ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

-ចំនួន ១.៤០០ USD (មួយពាន់បួនរយ ដុល្លាអាមេរិក) ក្នុងមួយឆ្នាំសិក្សា

-ចំនួន ៧៣០ USD (ប្រាំពីររយសាមសិប ដុល្លាអាមេរិក) ក្នុងមួយឆមាសសិក្សា

-លើកលែងតែក្នុងករណីដោយឡែក ដែលសម្រេចដោយសាកលវិទ្យាធិការ។

**ប្រការ៤.-តម្លៃសិក្សាក្រោយរយៈពេលសិក្សាអប្បរមា**

និស្សិតបណ្ឌិតដែលមិនទាន់បានបញ្ចប់ការសិក្សា ក្នុងរយៈពេលអប្បរមាសរុប ៣ឆ្នាំ អាចបន្តដំណើរការសិក្សាបន្ថែមទៀតបាន រហូតដល់រយៈពេលអតិប្បរមាសរុបចំនួន ៦ឆ្នាំ ហើយត្រូវបង់ថ្លៃសិក្សា ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

-ចំនួន ១.៨០០ USD (មួយពាន់ប្រាំបីរយ ដុល្លាអាមេរិក) ក្នុងមួយឆ្នាំសិក្សា

-ចំនួន ៩៥០ USD (ប្រាំបួនរយហាសិប ដុល្លាអាមេរិក) ក្នុងមួយឆមាសសិក្សា

-លើកលែងតែក្នុងករណីដោយឡែក ដែលសម្រេចដោយសាកលវិទ្យាធិការ។

**ប្រការ៥.-បដិភាគរបស់និស្សិតសម្រាប់ដំណើរការសិក្សា**

និស្សិតបណ្ឌិតត្រូវទទួលបន្ទុកចំណាយបដិភាគបន្ថែម សម្រាប់យន្តការការពារនិក្ខេបបទរៀងខ្លួនៗ ដូចខាងក្រោម ៖

-ការរៀបចំពិធី និង គណៈកម្មការវាយតម្លៃ ទាំងបីលើក មាន (១)ការពារគម្រោងស្រាវជ្រាវ (២) ការពារគម្រោងនិក្ខេបបទបណ្តោះអាសន្ន(កម្រិតមូលដ្ឋាន) (៣)ការពារបញ្ចប់(កម្រិតជាតិ)

-ការរៀបចំពិធីសិក្ខាសាលាបង្ហាញលទ្ធផលស្រាវជ្រាវ ចំនួន ពីរលើក

-ការចុះផ្សាយអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ចំនួន ពីរលេខ។

**ប្រការ៦**.-

ការិយាល័យសិក្សានិងស្រាវជ្រាវនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ជាអ្នកសម្របសម្រួលលើការរៀបចំពិធីការពារនិក្ខេបបទ ពិធីសិក្ខាសាលាបង្ហាញលទ្ធផលស្រាវជ្រាវ និងការចុះផ្សាយអត្ថបទស្រាវជ្រាវ បន្ទាប់ពីនិស្សិតបណ្ឌិតបានអនុវត្តរួចរាល់នូវប្រការ៥ នៃសេចក្តីសម្រេចនេះ ។

**ប្រការ៧**.-

គណៈគ្រប់គ្រង និស្សិតបណ្ឌិត សាស្ត្រាចារ្យណែនាំ ការិយាល័យសិក្សានិងស្រាវជ្រាវ និង ផ្នែកពាក់ព័ន្ធទាំងអស់នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៧

**សាកលវិទ្យាធិការ**

**ខ្ទង–លាង**

**ចម្លងជូន:**

-ក្រសួងអប់រំ យុវជន និងកីឡា

-អគ្គលេខាធិការដ្ឋាន គទក

ដើម្បីជូនជ្រាប

-ដូចប្រការ៧ ដើម្បីអនុវត្ត

-ឯកសារ-កាលប្បវត្តិ ស.អ.អ.